# 20 저는 설거지를 할게요

## ទុកឲ្យខ្ញុំជាអ្នកលាងចាន

**학습 안내**
ការណែនាំអំពីមេរៀន

| | |
|---|---|
| □ វត្ថុបំណងមេរៀន | ការពឹងពាក់ឲ្យធ្វើការងារផ្ទះ, ការនិយាយពីការងារផ្ទះ |
| □ វេយ្យាករណ៍ | -(으)ㄹ게요, -는 것 |
| □ ពាក្យថ្មី | ការបោសសម្អាត, ការងារផ្ទះ |
| □ ព័ត៌មាន · វប្បធម៌ | ប្រព័ន្ធបង់ប្រាក់ទៅតាមអត្រាបរិមាណរបស់សំរាម និងការបែងចែកប្រភេទសំរាម |

## 대화 1 ការសន្ទនា ១

Track 64



ធូអាន់និងរីហាន់មានបំណងចង់សម្អាតបន្ទប់។ ដំបូង សូមស្តាប់ការសន្ទនាឲ្យបាន២ដងជាមុនសិន រួចហើយចូរថាតាម។

투안 청소를 안 해서 방이 너무 더럽네요.
មិនបោសសំអាតអញ្ចឹងបន្ទប់កខ្វក់ណាស់។

리한 네, 바빠서 시간이 없었어요.
បាទ, ខ្ញុំអត់មានពេលទេ ពីព្រោះរវល់។

투안 지금 같이 청소할래요?
តើអ្នកចង់បោសសម្អាតវាជាមួយគ្នានៅពេលនេះទេ?

리한 그래요. 지금 해요.
បាទ, តោះធ្វើវាឥឡូវនេះ។
투안 씨는 방을 쓸어 주세요.
សូមធូអាន់ជាអ្នកបោសបន្ទប់។
저는 먼지를 닦을게요.
ទុកឲ្យខ្ញុំជាអ្នកជូតធូលី។

**그래요** បាទ/ចា៎(យល់ព្រម)
យល់ព្រមធ្វើតាមអ្វីដែលបាននិយាយពីខាងដើម។
- 가: 같이 운동하러 갈래요?
  តើអ្នកចង់ទៅហាត់ប្រាណជាមួយគ្នាដែរឬទេ?
  나: 그래요. 같이 가요.
  បាទ, តោះទៅជាមួយគ្នា។
- 가: 점심 때 김치찌개 먹을래요?
  តើចង់ហូបសម្លគីមឈីពេលថ្ងៃត្រង់នេះទេ?
  나: 그래요. 김치찌개 먹어요.
  ចា, តោះហូបសម្លគីមឈី។

**너무**ណាស់(ពិតជា, ខ្លាំង...)
ដែលលើសពីចំនួន ឬកំរិត ដែលបានកំណត់
- 비가 너무 많이 와요.
  ភ្លៀងធ្លាក់ខ្លាំងណាស់។
- 주말에 너무 늦게까지 잤어요.
  នៅចុងសប្តាហ៍ខ្ញុំបានក្រោកយឺតណាស់។
  (ខ្ញុំបានគេងជ្រុលខ្លាំង។)



តើអ្នកបានស្តាប់ និងថាតាមហើយឬនៅ? សូមឆ្លើយសំណួរខាងក្រោម។

1. 투안 씨의 방이 어때요? តើបន្ទប់របស់ធូអាន់យ៉ាងម៉េចដែរ?

2. 두 사람은 무엇을 하려고 해요? តើពួកគេទាំងពីរ មានបំណងចង់ធ្វើអ្វី?

**정답** 1. 더러워요. 2. 청소를 하려고 해요.

# 어휘 1 ពាក្យថ្មី ១ | 청소 ការបោសសម្អាត



ខាងក្រោមគឺជាឃ្លាផ្សេងៗដែលទាក់ទងទៅនឹងការបោសសម្អាត។ តោះ! ទៅមើលទាំងអស់គ្នាថាមានពាក្យអ្វីខ្លះ?



더럽다
កខ្វក់



깨끗하다
ស្អាត



어지럽다
រញ៉េរញ៉ៃ



정돈되어 있다
មានសណ្ដាប់ធ្នាប់



청소를 하다
បោសសម្អាត



청소기를 돌리다
ប្រើម៉ាស៊ីនបូមធូលី



정리하다
រៀបចំ



먼지를 떨다
បោសធូលី



쓸다
បោស



닦다
ជូត



쓰레기를 버리다
បោះចោលសំរាម



청소 도구
ឧបករណ៍បោសសម្អាត



빗자루
អំបោស



걸레
ក្រណាត់ជូត



휴지통
ធុងសំរាម



សូមកុំមើលពាក្យនៅខាងលើ ហើយសាកល្បងដោះស្រាយសំណួរ។

1. 그림에 맞는 표현을 〈보기〉에서 골라 넣으세요.

សូមជ្រើសរើសកន្សោមពាក្យពី<ឧទាហរណ៍>មកបំពេញឲ្យបានត្រឹមត្រូវទៅនឹងរូបភាព។



1) ______



2) ______



3) ______



4) ______

보기
닦다
쓸다
버리다
정리하다

정답 1) 쓸다 2) 닦다 3) 정리하다 4) 버리다

## 문법 1 វេយ្យាករណ៍ ១ | -(으)ㄹ게요

G20-1

យើងប្រើប្រាស់ '-(으)ㄹ게요' ភ្ជាប់នៅពីក្រោយកិរិយាស័ព្ទ ដើម្បីបង្ហាញពីឆន្ទៈក្នុងការធ្វើអ្វីមួយ។

| 자음(ព្យញ្ជនៈ) → **-을게요** | 모음(ស្រៈ), 자음 'ㄹ'(ព្យញ្ជនៈ 'ㄹ') → **-ㄹ게요** |
|---|---|
| 찾다 → 찾**을게요** | 주다 → **줄게요**<br>만들다 → 만**들게요** |

- 이따가 **전화할게요**. បន្តិចទៀតចាំខ្ញុំទូរសព្ទទៅ។
- 가: 내일은 지각하지 마세요. ថ្ងៃស្អែកសុំកុំមកយឺត។
  나: 네, 늦지 않고 일찍 **올게요**. បាទ, ខ្ញុំនឹងមកឲ្យលឿនមិនឲ្យយឺតទេ។

### 비교해 보세요 សូមសាកល្បងធ្វើការប្រៀបធៀប

**✔ '-(으)ㄹ게요' និង '-(으)ㄹ 거예요'**

'-(으)ㄹ게요' និង'-(으)ㄹ 거예요'បង្ហាញពីអ្វីដែលត្រូវកើតឡើងនៅពេលខាងមុខ។ នៅពេលដែលប្រធានជាមនុស្សទី១ '-(으)ㄹ 거예요' គឺបង្ហាញពីឆន្ទៈរបស់អ្នកនិយាយ, ប៉ុន្តែបើសិនជាប្រធានជាមនុស្សទី៣ គឺបង្ហាញពីការទស្សន៍ទាយឬការប៉ាន់ស្មាន។ '-(으)ㄹ게요' ប្រើប្រាស់នៅពេលនិយាយប្រៀបដូចជាយើងនឹងសន្យាជាមួយអ្នកដែលយើងកំពុងនិយាយជាមួយ។ ប្រធានរបស់ '-(으)ㄹ 거예요' អាចជាមនុស្សទី១,ទី២ ឬទី៣, ប៉ុន្តែប្រធានរបស់ '-(으)ㄹ게요'គឺត្រូវតែជាមនុស្សទី១។

- 리한 씨가 앞으로 열심히 **할 거예요**.(O)
  리한 씨가 앞으로 열심히 할게요.(X)



តើអ្នកយល់អំពីការប្រើប្រាស '-(으)ㄹ게요' ហើយមែនដែរឬទេ? បើអញ្ចឹងសូមមើលរូបភាព បន្ទាប់មកបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

2. 〈보기〉처럼 대화를 완성하세요. សូមបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

보기
가: 방을 닦으세요. សូមជូតបន្ទប់។
나: 네, 닦을게요. បាទ/ចា៎, ចាំខ្ញុំជាអ្នកជូត។

1) 가: 작업을 정리하세요.
   나: 네, ______________________.

2) 가: 누가 저하고 같이 갈래요?
   나: 제가 같이 ______________________.

3) 가: 투안 씨는 내일 뭘 준비할래요?
   나: 저는 과일을 ______________________.

4) 가: 사진을 찍어 줄래요?
   나: 좋아요, 제가 사진을 ______________________.

정답 1) 정리할게요 2) 갈게요 3) 준비할게요 4) 찍어 줄게요

## 대화 2 ការសន្ទនា ២

Track 65

តើអ្នកគិតថា ធូអាន់និងរីហាន់ ចូលចិត្តការធ្វើម្ហូបដែរឬទេ? ជាដំបូង សូមស្ដាប់ការសន្ទនាឲ្យបាន២ដង។ បន្ទាប់មក សូមដើរតួជាធូអាន់និងរីហាន់ ហើយថាតាមការសន្ទនា។

**투안** 어제 친구하고 불고기를 만들었어요.
ម្សិលមិញបានធ្វើ ប៊ូលកូគី ជាមួយមិត្តភក្ដិ។
정말 재미있었어요. វាពិតជាសប្បាយខ្លាំងណាស់។

**리한** 투안 씨는 요리를 하는 것이 재미있어요?
តើធូអាន់មានចំណាប់អារម្មណ៍នឹងការធ្វើម្ហូបដែរឬទេ?

**투안** 네, 전 정말 재미있어요.
បាទ, ខ្ញុំមានចំណាប់អារម្មណ៍ខ្លាំងណាស់។
리한 씨는요? ចុះរីហាន់វិញ?

**리한** 저는 재미없어요. 하지만 설거지는 괜찮아요.
ខ្ញុំគ្មានចំណាប់អារម្មណ៍ទេ។ ប៉ុន្តែការលាងចានគឺមិនអីទេសំរាប់ខ្ញុំ។

**투안** 그래요? 그러면 앞으로 요리는 제가 할게요.
អញ្ចឹងឬ? បើអញ្ចឹងពេលក្រោយ ម្ហូបទុកឲ្យខ្ញុំជាអ្នកធ្វើ។
설거지는 리한 씨가 하세요.
សូមរីហាន់ ជាអ្នកលាងចានចុះ។

**앞으로** លើកក្រោយ, ថ្ងៃមុខ,ថ្ងៃក្រោយ

- 앞으로 기숙사 청소는 제가 할게요.
  ថ្ងៃក្រោយបន្ទប់គេងក្នុងអន្តេវាសិកដ្ឋានទុកឲ្យខ្ញុំជាអ្នកសម្អាត។
- 가: 오늘도 지각을 했어요?
  តើថ្ងៃនេះអ្នកបានមកយឺតទៀតមែនទេ?
  나: 죄송합니다. 앞으로 늦지 않겠습니다.
  សុំទោស។ ថ្ងៃក្រោយខ្ញុំនឹងមិនមកយឺតទៀតទេ។

**하지만** ប៉ុន្តែ

ប្រើប្រាស់សម្រាប់ភ្ជាប់ឃ្លាខាងក្រោយជាមួយឃ្លាខាងមុខដោយនិយាយពីអត្ថន័យផ្ទុយគ្នា

- 저는 키가 커요. 하지만 제 동생은 키가 작아요.
  ខ្ញុំមានកំពស់ខ្ពស់។ ប៉ុន្តែប្អូនរបស់ខ្ញុំមានកំពស់ទាប។
- 한국 음식은 맛있어요. 하지만 좀 매워요.
  ម្ហូបកូរ៉េមានរសជាតិឆ្ងាញ់។ ប៉ុន្តែហិរបន្តិច។

តើអ្នកបានស្ដាប់ និងថាតាមហើយឬនៅ? សូមឆ្លើយសំណួរខាងក្រោម។

1. 투안 씨는 어제 뭘 했어요? តើម្សិលមិញ ធូអាន់បានធ្វើអ្វី?
2. 리한 씨는 요리하는 것을 좋아해요? តើរីហាន់ចូលចិត្តការធ្វើម្ហូបដែរឬទេ?

정답 1. 불고기를 만들었어요. 2. 아니요, 안 좋아해요.

### Tip 있다/없다 형용사 គុណនាម មាន/គ្មាន(មិនមាន)

'재미가 있어요'가 줄어서 '재미있어요'가 되었습니다. 한국어에는 이런 방식으로 만들어진 형용사가 있습니다.

យើងបង្រួម '재미가 있어요' ទៅជា '재미있어요' ។ ភាសាកូរ៉េមានគុណនាមដែលបង្កើតឡើងដោយរបៀបនេះ។

- 재미가 있다 → 재미있다 재미가 없다 → 재미없다
- 맛이 있다 → 맛있다 맛이 없다 → 맛없다
- 멋이 있다 → 멋있다 멋이 없다 → 멋없다

## 어휘 2 ពាក្យថ្មី ២ | 집안일 ការងារផ្ទះ



តោះ! ទៅមើលទាំងអស់គ្នាថាមានពាក្យអ្វីខ្លះដែលទាក់ទងនឹងការងារផ្ទះ?


장을 보다
ទៅផ្សារ


밥을 하다(짓다)
ដាំបាយ


음식을 만들다
ធ្វើម្ហូប


설거지를 하다
លាងចាន


밥솥
ឆ្នាំងបាយ


냄비
ឆ្នាំង


프라이팬
ខ្ទះ


주방 세제
សាប៊ូលាងចាន


빨래를 하다
បោកសំលៀកបំពាក់


세탁기를 돌리다
ប្រើប្រាស់ម៉ាស៊ីនបោកសំលៀកបំពាក់(បោកសំលៀកបំពាក់)


빨래를 널다
ហាលសំលៀកបំពាក់


빨래를 걷다
សាសំលៀកបំពាក់


옷을 다리다
អ៊ុតសំលៀកបំពាក់


옷을 개다
បត់សំលៀកបំពាក់


세탁세제
សាប៊ូបោកសំលៀកបំពាក់


다리미
ឆ្នាំងអ៊ុតសំលៀកបំពាក់



តោះ! សូមរំលឹកពីពាក្យដែលបានរៀននៅខាងលើម្តងទៀត បន្ទាប់មកសាកល្បងដោះស្រាយសំណួរ។
តើអ្នកបានដោះស្រាយហើយឬនៅ? តើពាក្យអ្វីដែលពិបាក? តើអ្នកបានធ្វើត្រូវប៉ុន្មានសំនួរ?

1. 그림에 맞는 표현을 〈보기〉에서 골라 넣으세요.
ចូរជ្រើសរើសកន្សោមពាក្យពី<ឧទាហរណ៍>ដាក់ទៅតាមរូបភាពអោយបានត្រឹមត្រូវ។


1)


2)


3)


4)

**보기**
장을 보다
옷을 다리다
빨래를 하다
설거지를 하다

정답 1) 설거지를 하다 2) 장을 보다 3) 옷을 다리다 4) 빨래를 하다

## 문법 2 វេយ្យាករណ៍ ២ | -는 것

G20-2

យើងប្រើប្រាស់ '-는 것' ភ្ជាប់ពីក្រោយកិរិយាស័ព្ទ សម្រាប់ប្តូរកិរិយាស័ព្ទទៅជានាម។

- 가: 옷을 **다리는 것**이 너무 어려워요. ការអ៊ុតសំលៀកបំពាក់គឺពិបាកណាស់។
  나: 그래요? 그럼 제가 다려 줄게요. អញ្ចឹងឬ? បើអញ្ចឹងទុកឲ្យខ្ញុំជាអ្នកអ៊ុតឲ្យ។
- 가: 왜 항상 밖에서 밥을 사 먹어요? ហេតុអ្វីតែងតែទិញបាយហូបនៅខាងក្រៅ?
  나: 저는 **요리하는 것**을 싫어해요. 그래서 사 먹어요. ខ្ញុំមិនចូលចិត្តការធ្វើម្ហូបទេ។ ដូច្នេះបានជាខ្ញុំទិញហូប។

### 크메르어와 한국어의 공통점과 차이점 ចំណុចដូចគ្នានិងខុសគ្នារវាងភាសាខ្មែរនិងភាសាកូរ៉េ

នៅក្នុងភាសាខ្មែរ នៅពេលដែលបំលែង កិរិយាស័ព្ទ ទៅជា នាម យើងប្រើពាក្យ "ការ" ដាក់ភ្ជាប់នៅខាងមុខកិរិយាស័ព្ទ។ ប៉ុន្តែនៅក្នុងភាសាកូរ៉េវិញ គេប្រើទម្រង់វេយ្យាករណ៍ '-는 것' ដាក់ភ្ជាប់ជាមួយ កិរិយាស័ព្ទ ឬគុណនាម ដើម្បីបំលែងទៅជានាម ហើយអាចប្រើប្រាស់វាដូចជានាមធម្មតាបាន។

- 비가 **와서** 축구를 못해요.
  ដោយសារតែ(ពីព្រោះ)ភ្លៀងធ្លាក់ ដូចនេះហើយខ្ញុំមិនបានលេងបាល់ទាត់ទេ។/ ខ្ញុំមិនបានលេងបាល់ទាត់ទេ ពីព្រោះមានភ្លៀងធ្លាក់។



តើអ្នកបានយល់អំពីការប្រើប្រាស់ '-는 것' ហើយមែនដែរឬទេ? បើអញ្ចឹង ចូរសាកល្បងបញ្ចប់ការសន្ទនាខាងក្រោម។

2. 그림을 보고 〈보기〉처럼 대화를 완성하세요.
សូមមើលរូបភាព បន្ទាប់មកចូរបញ្ចប់ការសន្ទនាដូច<ឧទាហរណ៍>។

보기



가: 요리가 힘들지 않아요? តើការធ្វើម្ហូបមិនពិបាកទេឬ?
나: 괜찮아요. 저는 음식을 만드는 것이 재미있어요.
មិនមានបញ្ហាទេ។ ខ្ញុំមានចំណាប់អារម្មណ៍ក្នុងការធ្វើម្ហូប។

1) 

가: 먼지가 너무 많아요.
나: 청소할 때는 창문을 ____________________이 좋아요.

2) 

가: 왜 빨래를 안 했어요?
나: 비가 올 때는 빨래를 ____________________이 안 좋아요.

3) 

가: 왜 옷을 모두 다려요?
나: 저는 옷을 ____________________이 재미있어요.

4) 

가: 왜 사진을 안 찍어요?
나: 저는 사진 ____________________을 안 좋아해요.

정답 1) 여는 것 2) 하는 것 3) 다리는 것 4) 찍는 것

## 활동 សកម្មភាព

〈보기〉처럼 친구하고 이야기해 보세요.

សូមសាកល្បងនិយាយជាមួយមិត្តភក្តិដូច<ឧទាហរណ៍>។

보기

가: 투안 씨는 집안일 하는 것을 좋아해요? តើធូអាន់ចូលចិត្តការធ្វើការងារផ្ទះដែរឬទេ?

나: 네, 좋아해요. បាទ, ចូលចិត្ត។

가: 무슨 일 하는 것을 가장 좋아해요? តើអ្នកចូលចិត្តធ្វើអ្វីជាងគេ?

나: 정리하는 것을 가장 좋아해요. ខ្ញុំចូលចិត្តការរៀបចំជាងគេ។

보기

가: 리한 씨는 집안일 하는 것을 좋아해요? តើរីហាន់ចូលចិត្តការធ្វើការងារផ្ទះដែរឬទេ?

나: 아니요, 안 좋아해요. ទេ, មិនចូលចិត្តទេ។

가: 무슨 일 하는 것을 가장 안 좋아해요? តើអ្នកចូលចិត្តធ្វើអ្វីជាងគេ?

나: 요리하는 것을 가장 안 좋아해요. ខ្ញុំចូលចិត្តការធ្វើម្ហូបជាងគេ។

| | 이름 ឈ្មោះ | 집안일 ការងារផ្ទះ |
|---|---|---|
| 보기 | 투안 ធូអាន់ | 정리하는 것을 가장 좋아해요.<br>ចូលចិត្តការរៀបចំទុកដាក់ជាងគេ។ |
| | 리한 រីហាន់ | 요리하는 것을 가장 안 좋아해요.<br>ចូលចិត្តការធ្វើម្ហូបជាងគេ។ |
| 1) | | |
| 2) | | |
| 3) | | |
| 4) | | |
| 5) | | |

# 쓰레기 종량제와 분리수거

## ប្រព័ន្ធបង់ប្រាក់ទៅតាមអត្រាបរិមាណរបស់សំរាម និងការបែងចែកប្រភេទសំរាម

**쓰레기 종량제** ប្រព័ន្ធបង់ប្រាក់ទៅតាមអត្រាបរិមាណរបស់សំរាម

쓰레기의 실제 배출량에 따라 수수료를 다르게 부과하는 제도입니다. 한국에서는 지정된 규격의 쓰레기봉투를 판매하고 그 봉투에만 쓰레기를 담아서 버리도록 하고 있습니다. 그리고 재활용이 가능한 쓰레기는 제외하여 재활용률을 높이는 효과가 있습니다. 1995년부터 전국적으로 실시되었습니다.

គឺជាប្រព័ន្ធបង់ប្រាក់ទៅតាមបរិមាណនៃសំរាម។ នៅប្រទេសកូរ៉េ គេលក់ថង់សំរាមទៅតាមទំហំដែលបានកំណត់ ហើយគ្រប់សំរាមទាំងអស់អាចបោះចោលបានតែក្នុងថង់នោះប៉ុណ្ណោះ។ ចំពោះសំរាមដែលអាចកែច្នៃឡើងវិញ គឺតម្រូវអោយចោលដោយឡែក ហើយវាមានប្រសិទ្ធភាពខ្ពស់ក្នុងការបង្កើនអត្រាកែច្នៃសំរាម។ វាត្រូវបានចាប់ផ្តើមអនុវត្តទូទាំងប្រទេសចាប់តាំងពីឆ្នាំ១៩៩៥មក។

**쓰레기 분리수거** ការបែងចែកសំរាម ទៅតាមប្រភេទសំរាមនីមួយៗ

<table>
<tr><td>일반 쓰레기<br>សំរាមធម្មតា</td><td></td><td rowspan="2">· 정해진 쓰레기봉투에 넣어야 합니다.<br>ត្រូវតែដាក់ចូលក្នុងថង់សំរាមដែលបានតម្រូវឲ្យដាក់។<br>· 정해진 장소에 버려야 합니다.<br>ត្រូវតែចោលនៅកន្លែងដែលបានតម្រូវឲ្យចោល។<br>· 음식물 쓰레기는 물기를 빼고 버려야 합니다.<br>កាកសំណល់អាហារត្រូវបង្ហូរទឹកចេញរួចសឹមចោល។<br>· 쓰레기봉투는 가까운 슈퍼마켓에서 살 수 있습니다.<br>ថង់សំរាមអាចទិញបាននៅផ្សារទំនើបដែលនៅជិត។<br>· 쓰레기봉투의 종류와 가격<br>ប្រភេទថង់សំរាមនិងតម្លៃ<br>– 일반 쓰레기봉투와 음식물 쓰레기봉투가 다릅니다.<br>ថង់ដាក់សំរាមធម្មតា និងថង់ដាក់កាកសំណល់អាហារ គឺខុសគ្នា។<br>– 규격별로 있습니다. (5ℓ, 10ℓ, 20ℓ, 30ℓ, 50ℓ, 75ℓ)<br>មានតាមទំហំ (5, 10, 20, 30, 50, 75)<br>– 지역별로 쓰레기봉투의 가격이 다릅니다.<br>តម្លៃនៃថង់សំរាមមានភាពខុសគ្នាទៅតាមតំបន់។</td></tr>
<tr><td>음식물 쓰레기<br>សំរាមកាក<br>សំណល់អាហារ</td><td></td></tr>
<tr><td>대형 쓰레기<br>ប្រភេទសំរាមខ្នាតធំ</td><td><br></td><td>· 대형 쓰레기에 스티커를 붙여야 합니다.<br>ប្រភេទសំរាមខ្នាតធំ ត្រូវតែបិទតែម។<br>· 스티커는 주민자치센터에서 살 수 있습니다.<br>តែមអាចរកទិញបាននៅ មជ្ឈមណ្ឌលសហគមន៍។<br>· 스티커는 인터넷으로도 살 수 있습니다.<br>តាមអ៊ីនធឺណេតក៏អាចទិញតែមបានដែរ។</td></tr>
<tr><td>재활용 쓰레기<br>សំរាមអាចកែច្នៃ</td><td></td><td>· 재활용 쓰레기는 분리해서 버려야 합니다.<br>សំរាមអាចកែច្នៃត្រូវបែងចែកហើយចោលដោយឡែក។<br>· 종이류, 빈병류, 플라스틱류가 있습니다.<br>មានដូចជា៖ ប្រភេទក្រដាស, ប្រភេទដបទទេ, ប្រភេទប្លាស្ទិច។</td></tr>
<tr><td>헌 옷,<br>형광등,<br>건전지<br>សំលៀកបំពាក់ចាស់ៗ,<br>អំពូលភ្លើង, ថ្មពិល</td><td></td><td>· 헌 옷은 헌 옷 수거함에 넣어야 합니다.<br>សំលៀកបំពាក់ចាស់ៗ ត្រូវដាក់ក្នុងកេសប្រមូលសំលៀកបំពាក់ចាស់ៗ។<br>· 형광등, 건전지는 전용 수거함에 넣어야 합니다.<br>អំពូលភ្លើង និងថ្មពិល ត្រូវដាក់ក្នុងកេសប្រមូលរបស់ទាំងនោះ។</td></tr>
</table>

# EPS-TOPIK 듣기 វិញ្ញាសាស្ដាប់ EPS-TOPIK

សំណួរទី១ និងទី២ គឺជាការមើលរូបភាព បន្ទាប់មកជ្រើសរើសប្រយោគដែលត្រឹមត្រូវ ។
សូមស្ដាប់ និង ជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

[1~2] 다음 그림을 보고 알맞은 것을 고르십시오.
សូមមើលរូបភាពខាងក្រោម បន្ទាប់មកចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវ។

Track 66

1. 

① ② ③ ④

2. 

① ② ③ ④

សំណួរបន្ទាប់ គឺជាការជ្រើសរើសចម្លើយដែលត្រឹមត្រូវទៅនឹងសំណួរ។
មុននឹងស្ដាប់ សូមពិនិត្យមើលចម្លើយជាមុនសិន។

[3~5] 질문을 듣고 알맞은 대답을 고르십시오. សូមស្ដាប់សំណួរ បន្ទាប់មកជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

3. ① 날씨가 흐려서 기분이 안 좋아요.
   ② 너무 달아서 저는 안 먹고 싶어요.
   ③ 약속 시간에 늦어서 너무 미안해요.
   ④ 청소를 너무 안 해서 방이 더러워요.

4. ① 괜찮아요. 지난번에 한 번 봤어요.
   ② 싫어요. 저는 운동을 별로 안 좋아해요.
   ③ 죄송해요. 제가 좀 바빠서 내일은 어려워요.
   ④ 미안해요. 무릎이 안 좋아서 닦는 것이 힘들어요.

5. ① 좋아요. 저하고 같이 걷어요.
   ② 글쎄요. 저는 아까 걷었어요.
   ③ 그래요. 제가 바로 걷어 줄게요.
   ④ 맞아요. 내일 저녁에 걷을 거예요.



## 듣기 대본 អត្ថបទនៅក្នុងវិញ្ញាសាស្តាប់

1. ① 여: 쓸어요. បោស។ ② 여: 닦아요. ជូត។
   ③ 여: 돌려요. ប្រើប្រាស់(ម៉ាស៊ីន)។ ④ 여: 버려요. ចោល។
2. ① 남: 장을 봐요. ទៅផ្សារ។ ② 남: 밥을 해요. ដាំបាយ។
   ③ 남: 음식을 만들어요. ធ្វើម្ហូប។ ④ 남: 설거지를 해요. លាងចាន។
3. 여: 방이 너무 더럽네요. បន្ទប់កខ្វក់ណាស់។
4. 남: 투안 씨는 방을 닦을래요? តើធួអាន់ចង់ជូតបន្ទប់ឬទេ?
5. 여: 제 빨래 좀 지금 걷어 주세요. សូមជួយប្រមូលសំលៀកបំពាក់របស់ខ្ញុំឲ្យខ្ញុំឥឡូវនេះបន្តិច។

정답 1. ④ 2. ④ 3. ④ 4. ④ 5. ③

## 확장 연습 លំហាត់អនុវត្តបន្ថែម

L-20

1. 이것은 무엇입니까? តើនេះជាអ្វី?



① ② ③ ④

2. 이 사람은 무엇을 하고 있습니까? តើមនុស្សម្នាក់នេះកំពុងតែធ្វើអ្វី?



① ② ③ ④

## 확장 연습 듣기 대본 អត្ថបទស្តាប់នៅក្នុងលំហាត់អនុវត្តបន្ថែម

1. 남: ① 밥솥입니다. គឺជាឆ្នាំងបាយ។ ② 냄비입니다. គឺជាឆ្នាំង។
   ③ 빗자루입니다. គឺជាអំបោស។ ④ 휴지통입니다. គឺជាធុងសំរាម។
2. 남: ① 옷을 개고 있어요. កំពុងតែបត់សំលៀកបំពាក់។
   ② 옷을 다리고 있어요. កំពុងតែអ៊ុតសំលៀកបំពាក់។
   ③ 빨래를 널고 있어요. កំពុងតែហាលសំលៀកបំពាក់។
   ④ 세탁기를 돌리고 있어요. កំពុងតែប្រើប្រាស់ម៉ាស៊ីនបោកសំលៀកបំពាក់(កំពុងបោកសំលៀកបំពាក់)។

정답 1. ④ 2. ①

# EPS-TOPIK 읽기 វិញ្ញាសាអាន EPS-TOPIK

សំណួរទី១ និងទី២ គឺជាការមើលរូបភាព បន្ទាប់មកជ្រើសរើសប្រយោគដែលត្រឹមត្រូវ ។
សូមជ្រើសរើសប្រយោគដែលត្រឹមត្រូវទៅនឹងរូបភាព។

[1~2] 다음 그림을 보고 맞는 문장을 고르십시오. សូមមើលរូបភាពខាងក្រោម បន្ទាប់មកជ្រើសរើសប្រយោគដែលត្រឹមត្រូវ។

1.



① 닦아요. ② 쓸어요.
③ 씻어요. ④ 빨아요.

2.



① 장을 봐요. ② 빨래를 해요.
③ 창문을 열어요. ④ 반찬을 만들어요.

សំណួរបន្ទាប់ គឺជាការអានប្រយោគឬក៏ការសន្ទនា ហើយធ្វើការជ្រើសរើសឃ្លា ដើម្បីបំពេញចន្លោះឲ្យបានត្រឹមត្រូវ។ សូមគិតអំពីអ្វីដែលអ្នកបានរៀនរួចហើយបណ្តើរ និងធ្វើការដោះស្រាយសំណួរបណ្តើរ។

[3~5] 빈칸에 들어갈 가장 알맞은 것을 고르십시오. ចូរជ្រើសរើសយកចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

3.
가: 방이 정말 ______________. បន្ទប់ពិតជារញ៉េរញ៉ៃណាស់។
나: 요즘 청소를 너무 안 해서 그래요. ពីព្រោះសព្វថ្ងៃនេះមិនដែលបានបោសសម្អាតទេ។

① 바빠요 ② 깨끗해요 ③ 가까워요 ④ 지저분해요

4.
가: 우리 같이 작업장을 청소할까요? តោះ! តើយើងគួរបោសសម្អាតកន្លែងធ្វើការជាមួយគ្នាទេ?
나: 좋아요. 제가 ______________. ល្អណាស់។ ទុកឲ្យខ្ញុំជាអ្នកបោសកន្លែងធ្វើការ។

① 작업장을 쓸게요 ② 작업장이 넓어요
③ 작업장에 없어요 ④ 작업장을 안 볼게요

5.
투안 씨, 저 리한이에요. 부탁이 있어요. 제가 오늘 아침에 옥상에 제 바지를 널었어요. 그런데 저는 오늘 기숙사에 못 들어가요 . 투안 씨가 오늘 저녁에 제 바지를 좀 __________ 주세요. 고마워요.

ធូអាន់, ខ្ញុំគឺរីហាន់។ ខ្ញុំមានសំណើមួយ។ ខ្ញុំបានហាលខោរបស់ខ្ញុំនៅដំបូល។ ប៉ុន្តែថ្ងៃនេះខ្ញុំមិនអាចត្រលប់ទៅអន្តេវាសិកដ្ឋានវិញបានទេ។ នៅពេលល្ងាច សូមធូអាន់ជួយប្រមូលខោរបស់ខ្ញុំផង។ អរគុណ។

① 해 ② 걷어 ③ 닦아 ④ 만들어

정답 1. ① 2. ③ 3. ④ 4. ① 5. ②



## 확장 연습 លំហាត់អនុវត្តបន្ថែម

[1~3] 빈칸에 들어갈 가장 알맞은 것을 고르십시오.
ចូរជ្រើសរើសចម្លើយដែលត្រឹមត្រូវបំផុតដើម្បីបំពេញចន្លោះ។

1. 작업장에 먼지가 많아서 ________을/를 했습니다. 바닥도 닦고 환기도 시켰습니다.
ដោយសារនៅការដ្ឋានធ្វើការ មានធូលីច្រើនពេកដូច្នេះខ្ញុំបានបោសសម្អាត។ បានជូតឥដ្ឋ និងប្តូរបរិយាកាសខ្យល់ចេញចូលរួចហើយ។

① 공부　② 청소　③ 운동　④ 노래

2. 청소를 안 해서 방이 너무 ________. 그래서 오늘 투안 씨와 함께 방을 쓸고 먼지를 닦았습니다.
ដោយសារមិនបានបោសសម្អាតទើបបន្ទប់កខ្វក់ណាស់។ ដូច្នេះខ្ញុំបានបោសបន្ទប់ និងជូតធូលីជាមួយធូអាន់។

① 더러웠습니다　② 비슷했습니다
③ 따뜻했습니다　④ 단정했습니다

3. 많은 사람들이 이용하는 공공장소에서는 예의를 지켜야 합니다. 함부로 쓰레기를 ________ 큰 소리로 떠들면 안 됩니다.
នៅកន្លែងសាធារណៈដែលមានមនុស្សជាច្រើនប្រើប្រាស់ យើងត្រូវមានសណ្តាប់ធ្នាប់។ មិនត្រូវចោលសំរាមផ្តេសផ្តាស ឬនិយាយឡូឡាទេ។

① 떨거나　② 쓸거나
③ 버리거나　④ 정리하거나

정답 1. ② 2. ① 3. ③

## 발음 ការបញ្ចេញសម្លេង

P-08

### សូមស្តាប់ដោយយកចិត្តទុកដាក់ រួចចូរថាតាម។

ក្នុងភាសាកូរ៉េ ព្យញ្ជនៈដែលអាចប្រើប្រាស់ជាជើង ឬបញ្ចេញសំលេងជាជើងគឺមានកំណត់។ ក្នុងនោះគឺមានតែ៧ប៉ុណ្ណោះដែលអាចប្រើប្រាស់ឬបញ្ចេញសំលេងជាជើងបាន។ ដូចជាព្យញ្ជនៈ ‘ㄹ’ គឺគេបញ្ចេញជាសម្លេង ‘l’ ឧទាហរណ៍ដូចជា ‘을’។

(1) 물, 길, 달, 얼굴　(2) 서울, 내일, 하늘, 거울
(3) 물 좀 주세요.　(4) 내일 봐요.